# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

៣៣៣❀៥៥

## ក្រុមហ៊ុន អេអេសអេហ្វ ស្ព័តធីង ហ្គូដ ឯ.ក

ASF SPORTING GOODS CO., LTD

## កិច្ចព្រមព្រៀង

## រវាង

## ក្រុមហ៊ុន អេអេសអេហ្វ ស្ព័តធីង ហ្គូដ ឯ.ក
## ជាមួយតំណាងកម្មករ ប្រធានក្រុម ប្រធានផ្នែក និង សហជីពមូលដ្ឋាន

នាព្រឹកថ្ងៃ ព្រហស្បតិ៍ ទី០៨ ខែធ្នូ ឆ្នាំ២០២២ វេលាម៉ោង ៨ : ៣០នាទី ក្រុមហ៊ុន អេអេសអេហ្វ ស្ព័តធីង ហ្គូដ ឯ.ក បានធ្វើកិច្ចព្រមព្រៀងមួយស្តីអំពី ការព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតចំនួន ២៣៣នាក់ (ស្រី ១៦០នាក់) ដែលមានកម្មករសរុប ចំនួន ៧៥៤នាក់ (ស្រី៤៧១) រយៈពេលពីរខែ ចាប់ពីថ្ងៃទី០៨ ខែធ្នូ រហូតដល់ថ្ងៃទី០៧ ខែ កុម្ភៈ ឆ្នាំ២០២៣ មូលហេតុក្នុងការព្យួរនេះ គឺដោយសារតែក្រុមហ៊ុនមិនមានការបញ្ជាទិញច្រើនដែលនាំអោយក្រុមហ៊ុនបន្តព្យួរក្នុងផ្នែកផលិតកម្មខ្លះបន្តទៀត ។ មូលហេតុនេះស្របតាមការកំណត់ក្នុងចំណុចទី១១ វាក្យខណ្ឌទី១ ប្រការ៧១ នៃច្បាប់ស្តីពីការងារ។ ហេតុនេះ យោងតាមវាក្យខណ្ឌទី២ ប្រការ៧២នៃច្បាប់ស្តីពីការងារខាងលើនេះ នាយកក្រុមហ៊ុន និង តំណាងកម្មករ ប្រធានក្រុម ប្រធានផ្នែក និងសហជីព បានព្រមព្រៀងគ្នាដូចខាងក្រោម ៖

១. នៅក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារក្រុមហ៊ុននឹងឧបត្ថម្ភប្រាក់ ១៥ ដុល្លារ ក្នុងមួយខែជូនកម្មករនិយោជិតទាំងអស់គ្នា ហើយ ការបើកប្រាក់ឧបត្ថម្ភនេះកម្មករនិយោជិតទាំងអស់ឯកភាពអោយក្រុមហ៊ុនបើកជូនលើកទី១នៅ ថ្ងៃទី១០ ខែ ធ្នូ ឆ្នាំ២០២២ និងលើកទី២ នៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០២៣។

បញ្ជាក់: ការចូលមកធ្វើការវិញ គឺនៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ២០២៣។

កិច្ចព្រមព្រៀងនេះត្រូវបានបញ្ចប់នៅវេលាម៉ោង ៩: ៣០នាទីព្រឹក ថ្ងៃខែឆ្នាំដដែល ដោយបរិយាកាសរីករាយ ស្និតស្នាល ក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងការយោគយល់គ្នាទៅវិញទៅមក។ ដើម្បីបញ្ជាក់ក្នុងកិច្ចព្រមព្រៀងនេះ គ្រប់ភាគីទាំងអស់បានចុះហត្ថលេខាឬផ្តិតស្នាមមេដៃ ទុកជាភស្តុតាងស្រាប់។

ហត្ថលេខា និងត្រា

នាយកក្រុមហ៊ុន

ស្នាមមេដៃតំណាងកម្មករ ប្រធានក្រុម ប្រធានផ្នែក និង សហជីព

មាស សៅម៉ា    រុន រដ្ឋា    ជា មាន    ស៊ី សេងហុង

ASF SPORTING GOODS CO., LTD.
KINGDOM OF CAMBODIA


ឃុត នន
ផាត់ ស្រីរ៉ែម
ញ៉ាច ទូច
ប៊ុន ស្រី
ឡៅ សៀង
សួន សុខនាង
ឡាញ់ គុយ
ជ័រ សុខចិត្ត
រ៉េត រិទ្ធ
យ៉ាន វណ្ណា
ចាន់ ធឿន
លី ស្រីអែម
សៀន សៀកលី
ណាំ ស៊ាង
មួន បូរី
ប៉ៅ ធីដា
ស៊ិន កៅដាង
សឿន ស្រីនាថ
ញ៉ិប សេង
ផាន សុជាតា
ដួង សារ៉េត
នូ ស្រីនិច
គក ស្រីកាត់
យន់ នាម
ណុប រស្មី
នួន ឈឿន